ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៣ ស.ស.ន

# សារជូនចំពោះជនរួមជាតិកម្ពុជា

****+****

*- សូមក្រាបថ្វាយបង្គំសម្តេចព្រះសង្ឃរាជ និងព្រះថេរានុថេរៈគ្រប់ព្រះអង្គ !*

*- បងប្អូនជនរួមជាតិទាំងអស់ជាទីគោរពស្នេហា !*

ថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០១៧ បានក្លាយជាទិវាប្រវត្តិសាស្ត្រដ៏សំខាន់មួយរបស់ជាតិកម្ពុជាទាំងមូល ដោយ គណៈកម្មាការបេតិកភណ្ឌពិភពលោកនៃអង្គការដើម្បីវប្បធម៌ វិទ្យាសាស្ត្រនិងអប់រំរបស់អង្គការសហប្រជាជាតិ (យូណេស្កូ UNESCO ) បានសម្រេចចុះ « **តំបន់ប្រាសាទសំបូរព្រៃគុក** » ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក តាមរយៈ DECISION 41 COM 8B.15, នៅក្នុងកិច្ចប្រជុំលើកទី ៤១ របស់ខ្លួន នៅទីក្រុង Krakow នៃប្រទេសប៉ូឡូញ តាមសំណើរបស់រាជរដ្ឋាភិបាលកម្ពុជា ។

នេះ គឺជាមោទនភាពថ្មីមួយទៀតសម្រាប់ប្រជាពលរដ្ឋ និងព្រះរាជាណាចក្រកម្ពុជាយើង ក៏ដូចជាសម្រាប់ប្រជាពលរដ្ឋនានានៅក្នុងតំបន់ និងពិភពលោក ដែល «**តំបន់ប្រាសាទសំបូរព្រៃគុក**» ត្រូវបានក្រុមប្រឹក្សាអន្តរជាតិស្តីពីប្រាង្គប្រាសាទ និងរមណីយដ្ឋាន (ICOMOS) ទទួលស្គាល់ថា ជាកំពូលស្នាដៃដ៏មហស្ចារ្យនៃស្ថាបត្យកម្មខ្មែរ និងមានតម្លៃសកលដ៏ចំណាន ហើយត្រូវបានបញ្ចូលទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ។

ការចុះបញ្ជីនេះ នឹងតម្រូវឱ្យកម្ពុជា និងសហគមន៍អន្តរជាតិទាំងមូលមានកាតព្វកិច្ចសហប្រតិបត្តិការជាមួយគ្នាការពារនូវបេតិកភណ្ឌសកលនេះ ហើយថែរក្សាជាសម្បត្តិវប្បធម៌ដែលជាកេរ្តិ៍មរតកសម្រាប់មនុស្សជំនាន់ក្រោយ ។ **តំបន់ប្រាសាទសំបូរព្រៃគុក** គឺជាបេតិកភណ្ឌខ្មែរទី ៣ ហើយ ដែលទទួលបាននូវលក្ខន្តិកៈដ៏ខ្ពង់ខ្ពស់ថ្លៃថ្នូរនេះ បន្ទាប់ពី**តំបន់ប្រាសាទអង្គរ** ត្រូវបានបញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅឆ្នាំ ១៩៩២ និង**ប្រាសាទព្រះវិហារ** ត្រូវបានដាក់បញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅឆ្នាំ ២០០៨ ។

ដូចករណីមុនៗដែរ ការដាក់ **តំបន់ប្រាសាទសំបូរព្រៃគុក** ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក គឺជាលទ្ធផលនៃកិច្ចដំណើរការងារដ៏យូរ និងលំបាកស្មុគស្មាញ ។ ការកសាងឯកសារនានា ពាក់ព័ន្ធនឹងការស្នើដាក់ «**តំបន់ប្រាសាទសំបូរព្រៃគុក**» ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ត្រូវបានចាប់ផ្តើមតាំងពីឆ្នាំ ២០១២ មកម្ល៉េះ ។ បន្ទាប់មក ការងារនេះត្រូវបានប្រិតប្រៀង និងសម្រិតសម្រាំងកាន់តែម៉ត់ចត់ថែមទៀតនាចុងឆ្នាំ ២០១៣ ស្របតាមទិសដៅណែនាំ

នៃការអនុវត្តអនុសញ្ញាស្តីពីការការពារបេតិកភណ្ឌពិភពលោក វប្បធម៌ និងធម្មជាតិដែលកម្ពុជាគឺជាហត្ថលេខី មុននឹងខ្ញុំព្រះករុណាខ្ញុំ ក្នុងឋានៈជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា លើកសំណើជាផ្លូវការទៅមជ្ឈមណ្ឌលបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ នៅដើមខែ មករា ឆ្នាំ ២០១៦ ។ ផ្អែកលើសំណើនេះរបស់រាជរដ្ឋាភិបាល មជ្ឈមណ្ឌលបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូបានបញ្ជូនអ្នកជំនាញរបស់ក្រុមប្រឹក្សាអន្តរជាតិស្តីពីប្រាង្គ-ប្រាសាទ និងរមណីយដ្ឋាន (ICOMOS) មកវាយតម្លៃ **«តំបន់ប្រាសាទសំបូរព្រៃគុក»** នៅខែ កញ្ញា ឆ្នាំ ២០១៦ ហើយទើបធ្វើសេចក្តីសម្រេចបញ្ចូលតំបន់ប្រាសាទនេះ ជាផ្លូវការទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅក្នុងកិច្ចប្រជុំលើកទី ៤១ របស់ខ្លួន នាថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០១៧ នៅវេលាម៉ោង ១៦:៣៧ នាទី ម៉ោងនៅទីក្រុង Krakow នៃប្រទេសប៉ូឡូញ ត្រូវនឹងម៉ោង ២១:៣៧ នាទី ម៉ោងនៅភ្នំពេញ ។

ជាការពិត ការចុះបញ្ជីនេះ គឺជាមហាសមិទ្ធផល និងជាកិត្យានុភាពដ៏ខ្ពស់ត្រដែតថ្មីមួយទៀតរបស់ជាតិយើង ដែលកើតចេញមកពីកិច្ចខិតខំប្រឹងប្រែងប្រកបដោយវិរិយភាពជាប់មិនដាច់ និងឥតរាថយរបស់រាជរដ្ឋាភិបាលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា រយៈពេលជាង ៣០ ឆ្នាំកន្លងមក ក្នុងការស្វះស្វែងនាំមកជូនប្រជាជនកម្ពុជានូវសុខសន្តិភាព ការបង្រួបបង្រួមជាតិ និងភាពសុខដុមរមនា ក៏ដូចជាក្នុងការដឹកនាំកសាង និងអភិវឌ្ឍជាតិ ក្នុងគ្រប់វិស័យ រួមទាំងការអភិរក្ស និងអភិវឌ្ឍន៍សម្បត្តិវប្បធម៌ និងប្រពៃណីដ៏មិនអាចកាត់ថ្លៃបានរបស់ជាតិកម្ពុជាយើងផងដែរ ។

ក្នុងឱកាសដ៏មហាប្រសើរនេះ ទូលព្រះបង្គំជាខ្ញុំសូមព្រះរាជានុញ្ញាតសម្តែងនូវអំណរព្រះគុណដ៏ជ្រាលជ្រៅវិសេសថ្វាយព្រះករុណាព្រះមហាក្សត្រ **ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ដែលព្រះអង្គទ្រង់តែងបានប្រោសប្រទាននូវការគាំទ្រយ៉ាងពេញទំហឹងជានិច្ច ចំពោះកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដើម្បីបុព្វហេតុជាតិ និងមាតុភូមិនៃយើង ។

ខ្ញុំក៏សូមយកឱកាសនេះ ថ្លែងនូវអំណរគុណ និងមូលវិចារណ៍ដ៏ថ្លៃថ្លាជូនចំពោះលោកជំទាវ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ព្រមទាំងសមាជិក- សមាជិកានៃគណៈប្រតិភូកម្ពុជាគ្រប់រូបរួមជាមួយមន្ត្រីជំនាញទាំងអស់ដែលមានការពាក់ព័ន្ធដែលបានខិតខំព្យាយាមលះបង់កម្លាំងកាយ ប្រាជ្ញា និងស្មារតី ប្រកបដោយភាពប៉ិនប្រសប់និងវិជ្ជាជីវៈខ្ពស់ ពុះពារជំនះគ្រប់ការលំបាកគ្រប់បែបយ៉ាងរហូតសម្រេចបាននូវការចុះបញ្ជី « **តំបន់ប្រាសាទសំបូរព្រៃគុក**» ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនាថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០១៧ នេះ ។

ខ្ញុំសូមថ្លែងអំណរគុណជាពិសេសផងដែរ ជូនចំពោះបណ្តាប្រទេសជាមិត្ត អង្គការយូណេស្កូ និងឥស្សរជនទាំងឡាយ ដែលបានទទួលស្គាល់នូវតម្លៃដ៏មហាស្ចារ្យជាសកលនៃ**តំបន់ប្រាសាទសំបូរព្រៃគុក** ហើយគាំទ្រសំណើរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការដាក់តំបន់ប្រាសាទនេះទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ដើម្បីជាផលប្រយោជន៍ដ៏ឧត្តុង្គឧត្តមរបស់មនុស្សជាតិទាំងមូល ។

ទន្ទឹមនេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងទឹកចិត្តរំភើបរីករាយឥតឧបមា ខ្ញុំព្រះករុណាខ្ញុំ សូមចែករំលែកនូវសមិទ្ធផលដ៏ធំធេង និងមោទនភាពជាតិដ៏ខ្ពង់ខ្ពស់នេះ ជាមួយនឹងព្រះតេជគុណព្រះសង្ឃគ្រប់ព្រះអង្គ និងជនរួមជាតិកម្ពុជាគ្រប់រូប ព្រមទាំងសូមសម្តែងនូវអំណរគុណដ៏ជ្រាលជ្រៅ និងស្មោះស្ម័គ្របំផុត ចំពោះប្រជាពលរដ្ឋ

គ្រប់ជាន់ថ្នាក់ទាំងអស់ ពិសេសបងប្អូនប្រជាពលរដ្ឋ ដែលបានផ្តល់យុត្តិធម៌ និងការគាំទ្រប្រកបដោយទឹកចិត្តស្នេហាជាតិដ៏បរិសុទ្ធជូនដល់គណបក្សប្រជាជនកម្ពុជា និងដល់ខ្ញុំព្រះករុណាខ្ញុំឱ្យដឹកនាំរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបុព្វហេតុជាតិ មាតុភូមិ សុខសន្តិភាព និងការអភិវឌ្ឍ ដែលបាននាំមកជូនប្រជាជាតិកម្ពុជាទាំងមូល នូវសមិទ្ធផលដ៏ធំធេងមិនអាចកាត់ថ្លៃបានច្រើនរាប់មិនអស់ រួមទាំងការដាក់ «តំបន់ប្រាសាទសំបូរព្រៃគុក» ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនាពេលនេះផង ។

ដើម្បីអបអរសាទរព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះ ខ្ញុំសូមណែនាំដល់គ្រប់ក្រសួង- ស្ថាប័ននៃរាជរដ្ឋាភិបាលនៅថ្នាក់ជាតិ និងគ្រប់ស្ថាប័ននៅថ្នាក់ក្រោមជាតិ រួមមាន: គ្រប់រាជធានី- ខេត្ត គ្រប់មន្ទីរជំនាញរាជធានី- ខេត្ត គ្រប់ក្រុង- ស្រុក- ខណ្ឌ និងគ្រប់ឃុំ- សង្កាត់ ព្រមទាំងសូមអំពាវនាវដល់ជនរួមជាតិកម្ពុជាគ្រប់រូប ដោយមិនប្រកាន់អាយុ ស្រទាប់វណ្ណៈ ពណ៌សម្បុរ មុខរបរ និងឋានៈសង្គម រួមគ្នាធ្វើការវាយគង ទូងស្គរ ទះប៉ោត និងគោះត្រដោកតាមគ្រប់មធ្យោបាយដែលខ្លួនមាននៅម៉ោង ១០ ព្រឹក នាថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ នៅគ្រប់ទីកន្លែងសាធារណៈសំខាន់ៗ រួមមានទីស្តីការក្រសួង- ស្ថាប័ន និងអង្គភាព គ្រប់សាលារាជធានីខេត្ត គ្រប់សាលា ក្រុង- ស្រុក- ខណ្ឌ គ្រប់សាលាឃុំ- សង្កាត់, គ្រប់វត្តអារាម និងសាលាបុណ្យ ព្រមទាំងគ្រប់ទីប្រជុំសហគមន៍នៅតាមភូមិ ឱ្យបានកុះករខ្ទរខ្ទារ ប្រកបដោយទឹកចិត្តមោទនៈ និងសប្បាយរីករាយ ចំពោះព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះ ។ ខ្ញុំសូមអំពាវនាវផងដែរ ដល់គ្រប់ស្ថានីយវិទ្យុ ទូរទស្សន៍ និងបណ្តាញព័ត៌មានទាំងអស់ មេត្តាចូលរួមសហការផ្សព្វផ្សាយព្រឹត្តិការណ៍ជាមោទនភាពជាតិដ៏មានសារៈសំខាន់នេះ ឱ្យបានទូលំទូលាយ និងអធិកអធមជាទីបំផុត ។

សូមសម្តេចព្រះសង្ឃរាជ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងជនរួមជាតិទាំងអស់ ទ្រង់បានប្រកប និងប្រកបដោយពុទ្ធពរបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៧*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**